## វិចារណកថាព័ត៌មាន

# ម.ស.ម.ក និង អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ ជំរុញឲ្យរដ្ឋាភិបាលធានាថា អនុក្រឹត្យស្តីពីការគ្រប់គ្រងអាស៊ីដត្រូវបានអនុវត្ត

### រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៣

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") និងអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ (CASC) ព្រួយបារម្ភពីកង្វះកិច្ចខិតខំប្រឹងប្រែងចំពោះការអនុវត្តន៍ អនុក្រឹត្យស្តីពីបែបបទ និងលក្ខខណ្ឌនៃការគ្រប់គ្រងអាស៊ីដខ្លាំង ("អនុក្រឹត្យ") ដែលបានអនុម័តនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣ ក៏ដូចជាការបញ្ចេញយោបល់មួយចំនួនរបស់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋាភិបាល) ពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុក្រឹត្យនេះ។ តាមចំណងជើងអត្ថបទមួយក្នុងកាសែត*ភ្នំពេញប៉ុស្តិ៍* ដែលបានចុះផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ មានចំណងជើងថា '*ការអនុវត្តន៍ដ៏ធូររលុងចំពោះការគ្រប់គ្រងអាស៊ីដខ្លាំង*' ដោយបានដកស្រង់សម្តីអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន ដែលថ្លែងថា "*ខ្ញុំគិតថា អ្នកភ្លេចគិតពី [អនុក្រឹត្យ] នោះ [...] យើងគ្មានតួនាទីក្នុងការគ្រប់គ្រងច្បាប់នោះទេ*"។ ជាងនេះទៅទៀតនោះមានតំណាងនានាមកពីក្រសួងដទៃៗ ដែលមានរាយនាមនៅក្នុងអនុក្រឹត្យដែលអ្នកសារព័ត៌មានបានទាក់ទងទៅរក បានបដិសេធមិនទទួលខុសត្រូវក្នុងការអនុវត្តន៍អនុក្រឹត្យនេះ ឬមិនបានដឹងថាមានអនុក្រឹត្យនេះ នោះផង។

ករណីវាយប្រហារដោយទឹកអាស៊ីដនៅក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះជាលំដាប់ មួយចំណែកគឺដោយសារតែការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំងនៅក្នុងខែធ្នូ ឆ្នាំ២០១១។ អង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដបានធ្វើកត់ត្រាឃើញថាមានករណីវាយប្រហារដោយទឹកអាស៊ីដចំនួន ៣ករណីប៉ុណ្ណោះ ដែលបណ្តាលឲ្យមានជនរងគ្រោះចំនួន ៦ នាក់ ក្នុងឆ្នាំ២០១៣ តាំងពីដើមឆ្នាំកន្លងមកនេះ។ ផ្ទុយទៅវិញ នៅក្នុងឆ្នាំ២០១០ ជាឆ្នាំមានចំនួនករណីវាយប្រហារដោយទឹកអាស៊ីដនៅក្នុងប្រទេសកម្ពុជា ខ្ពស់ជាខ្លាំង ដែលមានចំនួន ២៧ ករណីនៃការវាយប្រហារដោយទឹកអាស៊ីដ ដែលបណ្តាលឲ្យមនុស្សចំនួន ៣៦ នាក់ជាជនរងគ្រោះមុនពេលការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង។ ក៏ប៉ុន្តែ មានមនុស្សចំនួន ៣រូប បានស្លាប់នៅឆ្នាំនេះតាមរយៈការប្រើប្រាស់ទឹកអាស៊ីដ គឺ ម្នាក់ស្លាប់ដោយសារតែឧបទ្ទវហេតុចៃដន្យនិង២នាក់ទៀតស្លាប់ដោយសារអត្តឃាត ដែលនេះបង្ហាញថា នៅតែមានការចាំបាច់ដើម្បីបង្កើតនូវបទបញ្ញា និងការគ្រប់គ្រងដែលតឹងរ៉ឹងជាងនេះពីសំណាក់អាជ្ញាធរពាក់ព័ន្ធនានា។

ខណៈពេលដែល ម.ស.ម.ក និងអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ កោតសរសើរចំពោះរដ្ឋាភិបាលដែលបានអនុម័តនូវអនុក្រឹត្យនោះ ដើម្បីកំណត់ពី ការលក់ ការដឹកជញ្ជូន និងការស្តុកទុកអាស៊ីដខ្លាំង ប៉ុន្តែ ក៏មានការព្រួយបារម្ភថា នៅមានភាពស្រពិចស្រពិលចំពោះអនុក្រឹត្យនេះពាក់ព័ន្ធនឹងការអនុវត្តន៍នូវបញ្ញត្តិទាំងនោះ ហើយបើទោះបីជាមានការចុះឈ្មោះក្រសួង និងភ្នាក់ងារអនុវត្តច្បាប់នានាជាច្រើនក្តី ប៉ុន្តែ មិនមានការចែងច្បាស់ថា ភ្នាក់ងាររដ្ឋាភិបាលមួយណា ដែលទទួលខុសត្រូវពេញទំហឹងចំពោះការអនុវត្តន៍អនុក្រឹត្យនេះ។ ម.ស.ម.ក និងអង្គការជួយជនរងគ្រោះកម្ពុជាដោយសារអាស៊ីដ ជំរុញឲ្យក្រសួងទាំងឡាយដែលមានរាយនាមនៅក្នុងអនុក្រឹត្យនេះ កំណត់ជាអាទិភាពចំពោះការអនុវត្តន៍បទប្បញ្ញត្តិទាំងនេះ មានដូចជា៖ អ្នកតំណាងរបស់ក្រសួង និងភ្នាក់ងារនានា ដែលមានឈ្មោះក្នុងបញ្ជី គួរតែជួបប្រជុំគ្នាឲ្យបានធាប់តាមដែលអាចធ្វើទៅបាន និងធ្វើការកំណត់ផែនការសកម្មភាពចំពោះការអនុវត្តន៍ច្បាប់ និងដើម្បីលើកកម្ពស់ការយល់ដឹងពីបទប្បញ្ញត្តិនានានៅក្នុងអនុក្រឹត្យនេះ។

**កញ្ញា សន រ៉ាមណា អ្នកស្រាវជ្រាង ក្នុងគម្រោងបញ្ឈប់អំពើហិង្សាដោយអាស៊ីដរបស់ ម.ស.ម.ក មានប្រសាសន៍ថា៖**

*"ការប្រានចោលរបស់រដ្ឋាភិបាល ដែលបានបញ្ជាក់នៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ ចំពោះការអនុវត្តន៍អនុក្រឹត្យ បង្ហាញយ៉ាងច្បាស់ថា រដ្ឋាភិបាលមិនបានយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើហិង្សាទឹកអាស៊ីដនោះឡើយ។ ក្រសួង និងភ្នាក់ងារអនុវត្តច្បាប់នានា ដែលមានរាយឈ្មោះនៅក្នុងអនុក្រឹត្យនោះត្រូវតែរិះរកមធ្យោបាយផ្សេងៗ ដើម្បីអនុវត្តបទបញ្ញត្តិនេះ។ ដរាបណា ពុំមានការអនុវត្តន៍ច្បាប់ឲ្យបានពេញលេញនោះទេ ដរាបនោះ អំពើហិង្សានៅតែបន្តជាបញ្ហានៅក្នុងប្រទេសកម្ពុជា"។*

**លោកស្រី អ៊ែរីន ប៊្លូហ្វៀស អ្នកគ្រប់គ្រងគម្រោងរបស់ អង្គការជួយជនរងគ្រោះដោយសារអាស៊ីដ មានប្រសាសន៍ថា៖**

*"បន្ថែមពីលើការអនុវត្តន៍បទបញ្ជាអនុក្រឹត្យឲ្យបានពេញលេញ រដ្ឋាភិបាលត្រូវតែបរិច្ចាគនូវធនធាននានា ដើម្បីលើកកម្ពស់ការយល់ដឹងពីច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ជាពិសេស អាជីវករលក់ទឹកអាស៊ីដ កម្មករធ្វើការនៅតាមចម្ការកៅស៊ូ មន្ត្រីអនុវត្តច្បាប់ មន្ត្រីតុលាការ អ្នកផ្តល់ជំនួយផ្នែកច្បាប់ និងក្រុមបុគ្គលសំខាន់ៗដទៃទៀតដែលពាក់ព័ន្ធនឹងការតាក់តែងច្បាប់នេះ។ នេះគឺជាមធ្យោបាយតែមួយមុខប៉ុណ្ណោះ ដើម្បីធានាថា បទប្បញ្ញត្តិនានា នៅក្នុងអនុក្រឹត្យនេះ ត្រូវបានគោរព ហើយករណីអំពើហិង្សាដោយទឹកអាស៊ីដត្រូវបានទប់ស្កាត់"។*

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ +៨៥៥ (០) ១៧ ៦៥៥ ៥៩១ ឬតាមរយៈអ៊ីម៉ែល៖ ramanasorn@cchrcambodia.org ឬតាមរយៈលោកស្រី អ៊ែរីន ប៊្លូហ្វៀស តាមរយៈទូរសព្ទ+៨៥៥(០) ២៣ ៦៣៣ ៨០៧៧ ឬតាមរយៈអ៊ីម៉ែល៖info@thecasc.org។